










## តើអ្វីជាការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់?

ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (យូភីអ) គឺជាយន្តការរបស់អង្គការសហប្រជាជាតិ (អ.ស.ប) ដើម្បីពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សក្នុងរដ្ឋនីមួយៗនៅលើពិភពលោក។ ក្នុងអំឡុងពេល យូភីអ រដ្ឋដែលត្រូវបានពិនិត្យ ត្រូវបង្ហាញពីអ្វីដែលខ្លួនបានធ្វើពាក់ព័ន្ធ នឹងការគោរពសិទ្ធិ មនុស្ស ខណៈពេលដែលរដ្ឋជាសមាជិកផ្តល់ជាអនុសាសន៍ ដើម្បីលើកស្ទួយស្ថានភាពសិទ្ធិមនុស្ស។

## តើ យូភីអ ដំណើរការទៅដោយរបៀបណា?

យូភីអ ចែកចេញជា ៤ ដំណាក់កាល។

**(១) ការដាក់ជូនរបាយការណ៍**

រដ្ឋដែលនឹងត្រូវត្រួតពិនិត្យ អ.ស.ប អង្គការសង្គមស៊ីវិល គណៈកម្មការសិទ្ធិមនុស្សជាតិ អាចផ្ញើរបាយការណ៍របស់ខ្លួន ទៅក្រុមការងារ យូភីអ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសដែលនឹង ត្រូវត្រួតពិនិត្យ។ អ្នកអាចផ្ញើរបាយការណ៍ តាមប្រព័ន្ធអ៊ីនធើណែត តាមរយៈ ៖ https://uprdoc.ohchr.org/Account/Login.aspx?ReturnUrl=/

**(២) ការពិភាក្សាបែបអន្តរកម្ម**

កិច្ចត្រួតពិនិត្យនេះ នឹងធ្វើឡើងក្នុងពេលកិច្ចសន្ទនារវាង រដ្ឋដែលត្រូវត្រួតពិនិត្យ និងរដ្ឋជាសមាជិក អ.ស.ប ដទៃទៀត។ រដ្ឋដែលត្រូវត្រួតពិនិត្យ នឹងនិយាយមុនដោយបង្ហាញពីស្ថានភាព សិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន។ បន្ទាប់មក រដ្ឋដែលជាសមាជិក អ.ស.ប អាចផ្តល់យោបល់ សួរសំណួរ ឬក៏ផ្តល់អនុសាសន៍ស្តីពីរបៀបដែលរដ្ឋនោះអាចធ្វើសកម្មភាពដើម្បីធ្វើឲ្យស្ថានភាពសិទ្ធិមនុស្ស នៅក្នុងប្រទេសកាន់តែប្រសើរឡើង។
កិច្ចសន្ទនាបែបអន្តរកម្ម នឹងត្រូវបានធ្វើឡើងក្នុងអំឡុងកិច្ចប្រជុំរបស់ ក្រុមការងារ យូភីអ នៅទីក្រុងសឺណែវ។ ភាគីពាក់ព័ន្ធដទៃទៀត ដូចជា អង្គការសង្គមស៊ីវិល ស្ថាប័នជាតិ និងភ្នាក់ងារ អ.ស.ប អាចចូលរួមក្នុងការពិភាក្សា ប៉ុន្តែមិនអាចបញ្ចេញមតិក្នុងការពិភាក្សានេះបានទេ។

**(៣) ការទទួលយកអនុសាសន៍**

រដ្ឋនីមួយៗ អាចផ្តល់អនុសាសន៍ ដើម្បីពង្រឹងស្ថានភាពសិទ្ធិមនុស្ស នៅក្នុងប្រទេសដែលត្រូវត្រួតពិនិត្យឲ្យកាន់តែប្រសើរឡើង ប៉ុន្តែនៅចុងបញ្ចប់ រដ្ឋដែលត្រូវត្រួតពិនិត្យនោះទេដែលជាអ្នកសម្រេច ទទួលយក ឬបដិសេធអនុសាសន៍ទាំងនោះ។
នៅពេលរដ្ឋទទួលអនុសាសន៍រដ្ឋនោះប្តេជ្ញាចិត្តក្នុងការអនុវត្តអនុសាសន៍ទាំងនោះ និងត្រូវចាត់វិធានការចាំបាច់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។

**(៤) រយៈពេលធ្វើការតាមដាន**

ក្នុងចន្លោះពេលនៃការត្រួតពិនិត្យមួយ រហូតដល់មានការត្រួតពិនិត្យមួយទៀត ហៅថា «ការតាមដាន»។ ចន្លោះពេលនោះ ជាពេលដែលរដ្ឋត្រូវត្រួតពិនិត្យអនុវត្តន៍អនុសាសន៍ដែលខ្លួនបានទទួលយក។
ក្នុងដំណាក់កាលនេះ រដ្ឋត្រូវតែធ្វើការផ្លាស់ប្តូរជាចាំបាច់ ដើម្បីសម្រេចឲ្យបាននូវគោលបំណងនៃអនុសាសន៍ទាំងនោះ ដូចជា កំណែទម្រង់ផ្នែកច្បាប់ វិធានការគោលនយោបាយជាដើម....។

## វដ្តនៃ យូភីអ

- ការដាក់ជូនរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស →
- កិច្ចសន្ទនាបែបអន្តរកម្ម រវាងរដ្ឋត្រូវត្រួតពិនិត្យ និងរដ្ឋដែលជាសមាជិក អ.ស.ប →
- របាយការណ៍ចុងក្រោយជាមួយនឹងអនុសាសន៍ដែលរដ្ឋដែលត្រូវត្រួតពិនិត្យអនុម័តទទួលយក →
- ការអនុវត្តអនុសាសន៍ដែលទទួលបានពីការត្រួតពិនិត្យ →
- វគ្គ យូភីអ ថ្មី →

## តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីបាន?

- ផ្ញើរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋដែលត្រូវត្រួតពិនិត្យ
- ស្នើសុំឲ្យរដ្ឋដែលជាសមាជិក អ.ស.ប និង/ឬ ស្ថានទូតនៅក្នុងប្រទេសរបស់ខ្លួន សួរសំណួរជាក់លាក់និងផ្តល់អនុសាសន៍មួយចំនួនទៅរដ្ឋដែលត្រូវត្រួតពិនិត្យក្នុងអំឡុងពេលកិច្ចសន្ទនាបែបអន្តរកម្ម
- ចូលរួមនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សអំឡុងពេលការអនុម័តរបាយការណ៍ចុងក្រោយរបស់ យូភីអ
- តាមដានការអនុវត្តន៍អនុសាសន៍របស់រដ្ឋ
- លើកកម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយស្តីពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការអនុវត្តអនុសាសន៍។

## ប្រទេសកម្ពុជា និង យូភីអ

**នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤** ប្រទេសកម្ពុជានឹងត្រូវធ្វើការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ លើកទី២ ។ ការត្រួតពិនិត្យនេះនឹងពិនិត្យមើលទៅលើការគោរពសិទ្ធិមនុស្សរបស់កម្ពុជាក្នុងរយៈពេល ៤ ឆ្នាំកន្លងមក។

ក្នុងអំឡុងការពិនិត្យលើកដំបូង នៅឆ្នាំ ២០០៩ កម្ពុជា បានទទួលយកអនុសាសន៍ទាំង ១៣៨ ដែលរដ្ឋជាសមាជិកបានផ្តល់ជូនកម្ពុជា ប៉ុន្តែអនុសាសន៍ភាគច្រើនមិនត្រូវបានអនុវត្តនោះទេ។
អនុសាសន៍ ឆ្នាំ២០០៩ ៖ «ធានាឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ ដោយគ្មានការជ្រៀតជ្រែកពីនយោបាយ»
ប៉ុន្តែ កម្ពុជាមិនបានចាត់វិធានការណាមួយដើម្បីពង្រឹងនូវឯករាជ្យភាពរបស់ប្រព័ន្ធតុលាការនោះទេ។
អនុសាសន៍ ឆ្នាំ២០០៩ ៖ «ការពារសេរីភាពបញ្ចេញមតិ និងសិទ្ធិទាំងអស់របស់អ្នកការពារសិទ្ធិមនុស្ស» ប៉ុន្តែ តាំងពី ឆ្នាំ២០០៩ មក មានករណីលោក ឈុត វុទ្ធី ជាសកម្មជនផ្នែកបរិស្ថានត្រូវបានសម្លាប់ សកម្មជនដីធ្លី យ៉ោម បុប្ផា បានចំណាយពេល ៤៤៤ ថ្ងៃនៅក្នុងពន្ធនាគារ ហើយ អ្នកសារព័ត៌មាន ម៉ម សូណង់ដូ ត្រូវបានចាប់ឃុំខ្លួនជាច្រើនលើកច្រើនសា។ ថ្មីៗនេះ មានបាតុករត្រូវបានសម្លាប់ និងចាប់ខ្លួនដោយសារតែការចូលរួមក្នុងការធ្វើបាតុកម្ម។

## តួលេខពាក់ព័ន្ធនឹង យូភីអ

| | |
|---|---|
| ២០០៨ | ៖ ឆ្នាំដែល យូភីអ ចាប់ផ្តើម។ |
| ២០០៩ | ៖ ឆ្នាំដែលប្រទេសកម្ពុជា ស្ថិតក្រោយការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់។ |
| ៤២ | ៖ ចំនួនរដ្ឋដែលត្រូវបានពិនិត្យដោយ យូភីអ ក្នុងមួយឆ្នាំ។ |
| ១៣៨ | ៖ ចំនួនអនុសាសន៍ដែលផ្តល់ជូនទៅកម្ពុជា ក្នុងឆ្នាំ២០០៩។ |
| ៤៧ | ៖ ចំនួនរដ្ឋដែលផ្តល់អនុសាសន៍ទៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៩។ |
| ៤ ទៅ ៥ | ៖ ចំនួនចន្លោះឆ្នាំ នៃការត្រួតពិនិត្យម្តងៗ។ |
| ៣,៥ | ៖ ចំនួន ម៉ោងនៃកិច្ចសន្ទនាបែបអន្តរកម្មត្រូវបានធ្វើឡើង។ |
| ២ | ៖ ចំនួនថ្ងៃដែលរដ្ឋដែលត្រូវត្រួតពិនិត្យសម្រេចចិត្តថានឹងត្រូវទទួល ឬបដិសេធអនុសាសន៍។ |

## ទំនាក់ទំនង


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
អាស័យដ្ឋាន ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចំការមន ប្រអប់សំបុត្រលេខ ១៥០៦ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរសព្ទ ៖ (៨៥៥) ២៣ ៧២៦ ៩០១
សារអេឡិចត្រូនិច ៖ info@cchrcambodia.org
គេហទំព័រ ៖ http://www.cchrcambodia.org


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ម.ស.ម.ក ដែលបង្កើតឡើងនៅឆ្នាំ ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែល ធ្វើការលើកស្ទួយ និងការពារប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ដោយផ្តោតសំខាន់ទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។


ឧបត្ថម្ភបោះពុម្ពឡើងវិញដោយ
CIVIC SPACE INITIATIVE
ARTICLE 19 · World Movement for Democracy · CIVICUS · ICNL


CC BY NC SA

# ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) និងកម្ពុជា












## What is the Universal Periodic Review?

The Universal Periodic Review (UPR) is a United Nations (UN) mechanism to review the human rights practices of all the States in the world. During the UPR, States under review explain what they have done to respect human rights while other UN member States give recommendations on how it could improve human rights.

## How Does the UPR Work?

**The UPR is divided in four phases**

**(1) Submission of Reports**

The State under review, the UN, NGOs, National human rights commissions can send reports to the UPR Working Group about the human rights situation in the country under review.
You can send the report online: https://upr-doc.ohchr.org/Account/Login.aspx?ReturnUrl=/

**(2) Interactive Discussion**

The review takes place during a dialogue between the State under review and the other UN member States. The State under review speaks first, presenting the human rights situation in his country. Then UN Member States can make comments, ask questions or make recommendations on how the State could improve the human rights situation in its country.

The Interactive Discussion happens during the meeting of the UPR Working Group in Geneva. Other relevant stakeholders, such as NGOs, national institutions and UN agencies, can attend the discussion but cannot take the floor.

**(3) Acceptance of Recommendations**

Any State can make recommendations about the improvement of human rights in the country under review; but at the end it is the State under review who choose which recommendations will be accepted or not.

When the State accepts a recommendation, it commits itself to implement it and to take the necessary steps to protect and enhance the human right involved.

**(4) The "Follow-up" Period**

The period between one review and the next one is called the "follow-up." It is the moment during which the State under review implements the recommendations it received. At this point the State has to do the necessary changes to accomplish the goal of the recommendation, such as legislative reforms, policy measures...

## The UPR Cycle




## What Can Civil Society Do?

- Send a report on the human rights situation in the State under review;
- Ask UN member States and/or local embassies in their countries to ask specific questions and make some recommendations to the State under review during the interactive dialogue;
- Take the floor at the Human Rights Council during the adoption of the final UPR report;
- Monitor the implementation of the recommendations by the State;
- Raise awareness with the media on the State's commitment to implement the recommendations.

## Cambodia and the UPR

On 28 January 2014 Cambodia will do its second UPR Review.
It will look into the human rights performance of Cambodia over the last four years.

During its first review in 2009, Cambodia accepted all the 138 recommendations States made, but did not implement most of them.

2009 Recommendation: *"Ensure the independence of the judiciary, without any political intervention,"* but Cambodia did not take any actions to strengthen the independence of justice.

2009 Recommendation: *"Protect freedom of expression and the right of all human rights defenders,"* but since 2009; environmental activist Chut Wutty was killed; land rights activist Yorm Bopha spent 444 days in jail and journalist Mam Sonando was imprisoned several times. More recently, protesters were killed and arrested for participating in demonstrations.

## The UPR in Number

**2008** :Year the UPR started.
**2009** :Cambodia's first review under the UPR.
**42** :Number of States reviewed by the UPR per year.
**138** :Number of recommendations made to Cambodia in 2009.
**47** :Number of States that made recommendations to Cambodia in 2009.
**4 to 5** :Number of years between each review.
**3, 5** :Numbers of hours the interactive discussion lasts.
**2** :Number of days the State under review has to accept or reject recommendations.

## Contact

For more information, please contact:
#798, Street 99, Boeung Trabek, Khan Chamkarmon,
P.O Box 1506, Phnom Penh, Cambodia
Tel: (855) 23 72 69 01
Fax: (855) 23 72 69 02
E-mail: info@cchrcambodia.org
Web: www.cchrcambodia.org

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CCHR, founded in November 2002, is a non-aligned, independent, non-governmental organization that works to promote and protect democracy and respect for human rights – primarily civil and political rights throughout the Kingdom of Cambodia.

CC BY NC SA

Re-printed with support of:
CIVIC SPACE INITIATIVE
ARTICLE 19 · World Movement for Democracy · CIVICUS · ICNL

# The Universal Periodic Review (UPR) and Cambodia